# សេវាកំចាត់សមាសភាពចង្រៃក្នុងកុងតេន័រ និងមធ្យោបាយដឹកជញ្ជូនមុនពេលផ្ទុកទំនិញ

CAMPESTCONTROL

## DISINFECTING OF EMPTY CONTAINER AND CONVEYANCE BEFORE LOADING

(UPDATED BY TECHNICAL ADVISERY TEAM ON 30/01/2011)

សេវាកម្មដើម្បីមោទនៈជាតិខ្មែរ

អាស័យដ្ឋាន:
អគារលេខ ២១៦ ហាស់
ផ្លូវ ៦៣ សង្កាត់បឹងកេងកង១
ខណ្ឌចំការមន រាជធានីភ្នំពេញ
ADDRESS: #216H, 63St.,
BEUNGKENKANG I,
CHAMCARMORN, PHNOM PENH,
KINGDOM OF CAMBODIA
TEL: (855)12 943434/
(855)975577880
FAX: (855)23216655

ការកំចាត់សមាសភាពចង្រៃ (ដោយធូបទកម្ម) ក្នុងផលិតផលនៅមុនពេលផ្ទុក ឬបន្ទាប់ពីការផ្ទុកចូលទៅក្នុងកុងតេន័រ មិនមែនជាវិធីដែលអាចធានាគ្រប់គ្រាន់បានថាផលិតផលនោះ ពិតជាទទួលបាននូវអនុលោមភាពតាមការតម្រូវរបស់រដ្ឋាភិបាលប្រទេសនាំចូលឡើយ។ សំបកកុងតេន័រ និងមធ្យោបាយដឹកជញ្ជូន ត្រូវបានប្រើប្រាស់ឡើងវិញ បន្ទាប់ពីការផ្ទុកទំនិញផ្សេងៗ ដែលមានប្រភពខុសៗគ្នា ជាច្រើនលើករាប់មិនអស់ ដែលជាករណីដែលអាចប្រឈមនឹងហានិភ័យនៃការចំលងសមាសភាពចង្រៃចូលមកទំនិញថ្មីដែលនឹងត្រូវផ្ទុក។ ប្រភេទ និងប្រភពទំនិញដែលធ្លាប់ផ្ទុកពីមុនទាំងនោះ អាចជាប្រភពចំលងចូលទៅក្នុងទំនិញថ្មី នូលសមាសភាពចង្រៃដែលមិនមានវត្តមាននៅកម្ពុជា ឬ ដែលពិភពលោកភ័យខ្លាច ឬហាមឃាត់។ ការទប់ស្កាត់ការរាលដាលឆ្លងសមាសភាពចង្រៃ ក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលជាលក្ខខ័ណ តម្រូវនៃវិធានការអនាម័យ និងភូតគាមអនាម័យ មិនមែនតែតម្រូវឱ្យសំឡាប់តែសមាសភាពចង្រៃដែលកំពុងមានវត្តមានក្នុងផលិតផលនោះទេ តែវត្តមានសមាសភាពចង្រៃរស់ ឬងាប់ ឬសត្វដទៃដែលយើងមិនយល់ថាចង្រៃ (ដូចជាខ្យងសោក) ទោះនៅខាងក្នុង ឬ តោងលាក់ខ្លួនជាប់ផ្ទៃ ខាងក្រៅកុងតេន័រ ឬមធ្យោបាយដឹកជញ្ជូន ក៏ជាឧបស័គ្គដែលអាចធ្វើឱ្យទំនិញដែលល្អស្អាត មិនទទួលបានអនុលោមភាព (មិនអនុញ្ញាតឱ្យនាំចូល ឬបញ្ជូនត្រឡប់ក្រោយ ឬ កំទេចចោល) នៅពេលដឹកជញ្ជូនទៅដល់ច្រកទ្វារនៃនៃប្រទេសនាំចូល។

ហេតុនេះការសំអាត និងរំងាប់សមាសភាពចង្រៃក្នុងសំបកកុងតេន័រ ឬមធ្យោបាយដឹកជញ្ជូន នៅមុនពេលផ្ទុកទំនិញ ជាការចាំបាច់ដែលមិនអាចមើលរំលងបាន បើទោះជាមិនមែនជាលក្ខខ័ណតម្រូវរបស់រដ្ឋាភិបាលប្រទេសនាំចូល ឬ មិនបានតម្រូវដោយភាគីទទួលទិញ។

ការសំអាត និងរំងាប់សមាសភាពចង្រៃ ក្នុងសំបកកុងតេន័រ និង មធ្យោបាយដឹកជញ្ជូន នៅមុនពេលផ្ទុកទំនិញ មិនមែនជាការងារងាយស្រួល ដូចការកំចាត់មូសតាមលំនៅស្ថានឡើយ ដែលការជ្រើសរើសប្រើសេវាមិនត្រឹមត្រូវ បង្កឱ្យប៉ះពាល់ដល់គុណភាពទំនិញ និង បង្កើនភាពមិនអនុលោមកាន់តែស្មុកស្មាញ។ សេវាឯកទេសកម្មក្នុងការកំចាត់សត្វល្អិត របស់ក្រុមហ៊ុនខេមផេសខិនត្រូល បានកំណត់ចាត់ចែងសេវាដោយឈរលើគោលការណ៍ អនុលោមភាព និង សង្គតភាព ទៅនឹងលក្ខខ័ណដូចខាងក្រោម:

- លក្ខខ័ណបច្ចេកទេសតម្រូវដោយប្រទេសដែលនឹងត្រូវនាំចូល ក្នុងការសំអាត និងរំងាប់សមាសភាពចង្រៃ ក្នុងសំបកកុងតេន័រ និង មធ្យោបាយដឹកជញ្ជូន នៅមុនពេលផ្ទុកទំនិញ (ជាលក្ខខ័ណដែលខុសៗគ្នា)
- ប្រភេទទំនិញដែលនឹងត្រូវផ្ទុក (ផលិតផលស្បៀងអាហារ ពូជដំណាំ វាយនភ័ណ្ឌ សង្ហារឹម ជាដើម)
- ប្រភេទសារធាតុគីមីដែលប្រើក្នុងការសំអាត និងរំងាប់សមាសភាពចង្រៃ ត្រូវតែមានអំពើរហ័ស ឆាប់បែកធាតុពុល មិនមានជាតិប្រេង គ្មានក្លិន គ្មានព័ណ៌ មិនបំពានទៅនឹងបញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា និងស្របតាមគោលការណែនាំជាអន្តរជាតិ។ កំរិត និងវិធីប្រើប្រាស់ ត្រូវធានាដល់ការមិនបន្សល់ ជាតិពុល ដែលបង្កឱ្យប៉ះពាល់សុវត្ថិភាពអាហារ ឬ គុណភាព ផលិតផលដែលនឹងផ្ទុក
- ការសំអាត រាប់ទាំងការបោសសំអាតចេញនូវសំណល់ផលិតផល កំទេចកំទីផ្សេងៗ សមាសភាពចង្រៃទោះងាប់ឬរស់ នៅខាងក្នុង ឬខាងក្រៅ និងសត្វផ្សេងទៀត ទោះចាត់ថាជាសត្វធម្មតាដែលមាននៅកម្ពុជា ព្រោះជួនកាលវាត្រូវបានចាត់ជាប្រភេទឧត្បាតឆ្លងដែន (Invasive Aliens Species) ដោយប្រទេសដែលនឹងត្រូវនាំចូល។